អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## សំណុំរឿង ០០២/០២ នឹងត្រូវជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងបច្ចុប្បន្ន

នៅថ្ងៃនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញអនុស្សរណៈមួយ ដោយបានជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលថា ប្រធានអង្គជំនុំជម្រះសាលាដំបូងមិនស្នើឲ្យតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់នានាដែលនៅសេសសល់នៅដំណាក់កាលទីពីរនៃសំណុំរឿង ០០២ នេះទេ។

អនុស្សរណៈនេះបានចេញបន្ទាប់ពីមានអនុសាសន៍ពីអង្គជំនុំជម្រះតុលាការកំពូល ដែលស្នើឲ្យប្រធានអង្គជំនុំ-ជម្រះសាលាដំបូង “ពិនិត្យលទ្ធភាពដែលមានស្រាប់” ដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរសម្រាប់ជំនុំជម្រះលើសំណុំរឿង ០០២/០២ ដោយយល់ឃើញថា ដើម្បីជាការពន្លឿនកិច្ចដំណើរការនីតិវិធី ហើយដែលបញ្ហានេះត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីសប្តាហ៍មុន។

នៅក្នុងអនុស្សរណៈរបស់ខ្លួន ប្រធានអង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើភាពមិនច្បាស់លាស់តាមផ្លូវច្បាប់ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនេះ ក៏ដូចជាពេលវេលាដែលត្រូវការសម្រាប់ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ និងការត្រៀមរៀបចំរឿងក្តី មុននឹងប្រធានអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរដើម្បីជំនុំជម្រះលើអង្គហេតុដែលនៅសេសសល់នោះ នឹងមិនអាចប្រព្រឹត្តទៅបានឆាប់រហ័សជាងកិច្ចដំណើរការនីតិវិធីជាមួយនឹងក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្ន ដែលពួកគាត់បានយល់ដឹងអំពីសំណុំរឿងរួចហើយ នោះទេ។

ប្រធានអង្គជំនុំជម្រះសាលាដំបូងបានជម្រាបជូនប្រធានការិយាល័យរដ្ឋបាលថា យោងតាមហេតុផលខាងលើនេះ អង្គជំនុំជម្រះសាលាដំបូងនឹងចេញផែនការការងារសម្រាប់សំណុំរឿង ០០២/០២ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយក្នុងនោះកំណត់ដំណាក់កាលសំខាន់ៗ និងសកម្មភាពចាំបាច់នានា មុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២/០២។

នៅក្នុងសំណុំរឿង០០២ នួន ជា និង ខៀវ សំផន ប្រឈមនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។ ការជំនុំជម្រះដំណាក់កាលទីមួយប្រឆាំងនឹងជនជាប់ចោទ ត្រូវបានបញ្ចប់ដោយការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងខែ តុលា ឆ្នាំ ២០១៣ ហើយសាលក្រមលើការជំនុំជម្រះដំណាក់កាលទីមួយនេះគ្រោងនឹងចេញនៅក្នុងអំឡុងត្រីមាសទីពីរ ក្នុងឆ្នាំ ២០១៤ ខាងមុខនេះ។

អនុស្សរណៈទាំងមូលមានដាក់ផ្សាយនៅលើគេហទំព័រនៃ អ.វ.ត.ក៖
http://www.eccc.gov.kh/sites/default/files/documents/courtdoc/2013-12-20%2016:13/E301_4_KH.pdf

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យ
ទូរសព្ទដៃ៖ +855 (0) 12 488 156
ទូរសព្ទលើតុ៖ +855 23 861 564
អ៊ីម៉ែល៖ neth.pheaktra@eccc.gov.kh

លោកស្រី Yuko MAEDA
មន្ត្រីកិច្ចការសាធារណៈ
ទូរសព្ទដៃ៖ +855(0) 12 488 319
ទូរសព្ទលើតុ៖ +855 23 861 639
អ៊ីម៉ែល៖ maeday@un.org